# ឈ

**ឈ** ព្យញ្ជនៈ ទី ៤ ក្នុងវគ្គទី ២ ជាឃោសៈ មានសំឡេងកើតក្នុងពិតាន ពីត្រង់ក្រអូមមាត់ ។ ជាធនិត-ឃោសៈ, មានសំស្រ្តីឥតមានឈាលីមានសំឡេងជា *ឋ្ហ* ។

**ឈប** *កិ.* សម្ដីពោលបង្គួសឹង ក្លាយមកអំពីពាក្យ *ឈប់* ជាពាក្យប្រែក្រលបញ្ឈប់ចលស្ទមានតោជាដើម ឲ្យឈប់ ឲ្យបង្អង់ តាមសញ្ញាដែលបានបង្គាប់ ដែលធ្លាប់ប្រើប្រាស់មក, ដោយសេចក្ដីបង្គាប់ថា *ឯធីហូវឈប់!* ឬថា *ហួវឈប់!* ។

**ឈប់** *កិ.* បង្អង់នៅស្ងៀម, លើកលែងធ្វើ; លែងប្រព្រឹត្ត: *កំឈប់រៀនហើយ, ឈប់សិន ចាំខ្ញុំផង!*

**ឈម** *កិ.* ផ្ទោះមុខពាក្យ, ល្បោក ឬសម្ដីផ្ទោះទៅរកអ្នកម្ដុយ: *កុំឈមកុំឈរជិត ក្រែងមិនគត់ចន់ក្ដីកោះ កុំល្បងល្បងនោះនោះ គួរឲ្យទោះឲ្យដើរចេញ* (សាស្រ្តាច្បាប់ប្រុស) ។

**ឈរ** *កិ.* បិតរពេញជំហរ ដើងជាត់ត្រង់, ជាឈ្មោះឥរិយាបថមួយ ក្នុងឥរិយាបថទាំង ៤ គឺ *ដើរ, ឈរ, អង្គុយ, ដេក* ។ ស្ថិតនៅ, នៅស្ដីចិកជការ: *កជការត្រូវបាត់ឈរត… ឲ្យទៅឈរនៅខត្រស្វាយរៀង; ខ្ញុំបានឈរធ្វើកជការទីអភិបាលខេត្ត នៅខេត្តកំពតអស់ ៤ ឆ្នាំ* ។ នៅត្រឹមមិនឡើងមិនចុះ, មិនត្រាន់បើមិនរីកឡើង (ដំនំ): *ដំនឹឈរឲ្យមើលយូរណាស់ មិនតែកត្រូវមើលគួរ* ។ ឬ *ន.* អក្សរដែលមានខ្លួនត្រង់: *អក្សរឈរ* ។

**ឈាន ១** *កិ.* លើកជើងដើរ, យាសជើងបោះជំហានទៅ: *ឈានជើងដើរ* ។

**ឈាន ២** *ន.* (បា.; សំ. *ធ្យាន*) ការសម្ងំអារម្មណ៍ដែលជាគម្ពុតាសមាធិ : *ចម្រើនឈាន, ចូលឈាន;* ឈានមាន ៤ ថ្នាក់ គឺថ្នាក់ទី ១ ហៅ *បឋមជ្ឈាន* មានអង្គ ៥ គឺ ១- *វិតក្កៈ* សេចក្ដីនឹករំលោះផ្ទោះទៅរកអារម្មណ៍ដែលកំពុងការពារ; ២- *វិចារៈ* សេចក្ដីពិចារណាអារម្មណ៍ដែលកំពុងការពារ; ៣- *បីតិ* សេចក្ដីឆ្អែតចិត្ត; ៤- *សុខៈ* សេចក្ដីសប្បាយក្នុងចិត្ត; ៥- *ឯកគ្គតា* ដំណើរមូលចិត្តស្ងប់នៅក្នុងអារម្មណ៍តែមួយ (អង្គទាំង ៥ នេះ សំដៅចំពោះតែអារម្មណ៍ដែលស្ងប់ស្ងាត់ពាក្យកមគុណ); ថ្នាក់ទី ២ ហៅ *ទុតិយជ្ឈាន* មានអង្គ ៣ គឺលះ *វិតក្កៈ* និង *វិចារៈ* ចេញ នៅសល់តែ *បីតិ* និង *សុខៈ* ដែលកើតជាប់មកអំពីសមាធិរបស់បឋមជ្ឈាន ជា ៣ នឹង *ឯកគ្គតា*; ថ្នាក់ទី ៣ ហៅ *តតិយជ្ឈាន* មានអង្គ ២ គឺលះ *បីតិ* ចេញ នៅសល់តែ *សុខៈ* និង *ឯកគ្គតា*; ថ្នាក់ទី ៤ ហៅ *ចតុត្ថជ្ឈាន* មានអង្គ ២ ដែរ លះ *សុខៈ* ចេញ ចិត្តក្លាយទៅជា *ឧបេក្ខា* គឺព្រងើយព្រងើយ ជា ២ នឹង *ឯកគ្គតា* ។ ឈានទាំង ៤ ថ្នាក់នេះ ហៅថា *រូបជ្ឈាន* មានរូបធម៌ជាអារម្មណ៍រាប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនកាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ចូលប្រទះសេចក្ដីសុខសប្បាយឧត្ដម ផ្ដាច់ពីលោកាមិសជាតិអ្វីៗ ទាំងអស់ (ម. ព. *រូបជ្ឈាន, រូបធម៌, រូបាវចរភូមិ, សមាធិ, អប្បនាសមាធិ, កម្មដ្ឋាន* ផង) ។ បើរៀងក្នុងពីខាងដើមសព្ទដទៃទៀត អ. ថា. ឈានៈ ដូចជា *ឈានចិត្ត* (—ចិត) ចិត្តដែលបានសម្រេចឈាន ។ *ឈានផល* (—ផល់) ផលរបស់ឈាន, សេចក្ដីសម្រេចប្រយោជន៍ដែលកើតអំពីឈាន ។ *ឈានពល* (—ពល់) កម្លាំងនៃឈាន ។ *ឈានសុខ* (—សុក) សុខដែលកើតអំពីឈាន ។ *ឈានឫទ្ធិ* (—រឹត; បា. *ឈាន + ឥទ្ធិ;* សំ. *ធ្យាន + ឫទ្ធិ*) ឫទ្ធិនៃឈាន, ឫទ្ធិដែលកើតអំពីឈាន ។ *ឈានានុភាព* (—ភាប; បា. *ឈាន + អានុភាវ*) អានុភាព, អំណាច, តេជះនៃឈាន ។ ល ។

**ឈាន** — (មើលក្នុងពាក្យ *ឈាន*) ។

**ឈាបនកិច្ច** (ឈាប៉ៈន៉ៈកិច) *ន.* (បា.) ការដុតសាកសព; ពាក្យនេះ សម្រាប់ប្រើជាសាធារណៈ មិនចំពោះបុគ្គល ។ មានន័យឲ្យប្រើតាមលំដាប់ជាន់ខ្ពស់, កណ្ដាល, ទាបផ្សេងៗគឺ សម្រាប់ព្រះបរមសពនៃព្រះមហាក្សត្រ, សម្ដេចព្រះវររាជជននី, សម្ដេចព្រះអគ្គមហេសី, ព្រះសពសម្ដេចព្រះមហាសង្ឃរាជ, ព្រះអង្គម្ចាស់, អ្នកអង្គម្ចាស់ ហៅថា *ថ្វាយព្រះភ្លើង;* សម្រាប់សពនាម៉ឺនមន្ត្រីទាំងតូចធំក្រសួងប្រជាពលរដ្ឋមានកេរ្តិ៍ឈ្មោះ ហៅថា *បូជាសព;* សម្រាប់បព្វជិតទាំងតូច ហៅថា *បូជា* ឬ *បូជាសព;* សម្រាប់ក្រសួងប្រជាទាំងតូច ហៅថា *បូជាសព* ឬ *ធ្វើឈាបនកិច្ច;* សម្រាប់ជនទោសកម្មវិធី ហៅថា *ដុត* ឬ *ដុតខ្មោច* ។

**ឈាបនដ្ឋាន** (ឈា-ប៉ៈន័ត-ឋាន) *ន.* (បា.) ទីសម្រាប់ធ្វើឈាបនកិច្ច, កន្លែងសំលាយសាកសព : *គេប្រើនកសាងឈាបនដ្ឋានជាសាធារណៈ នៅក្បែរវត្ត ឬក្បែរព្រៃវត្ត* ។

**ឈាម** *ន.* អាការៈទី (ធាតុទឹក) សម្បុរក្រហម ផ្សំជ្រាបសព្វសព៌ៃក្នុងសព៌ាង្គកាយ ។

**ឈាវ** *កុ.* ឬ *កិ. វិ.* ដែលរង្គើល, ខ្ទយៗ, ល្ហោះៗ, ឬយឺតមួយពេល: *ស្ពានឈាវ, សំទូងឈាវៗ, ទៅមកឈាវ* (ប្រើតាមទម្លាប់ស្រុក) ។

**ឈិង** *ន.* ឈ្មោះគ្រឿងភ្លេងមួយប្រភេទក្នុងវង់ភ្លេងខ្មែរ: *ភ្លេងខ្មែរខ្វះឈិង មិនស្កប់ពីរោះ* ។

**ឈឹង** ១ *កុ.* ស្ងាត់ស្ងៀមសព្ទ, ស្ងប់ស្ងាត់, ស្ងៀម, ស្ងង់: *ស្ងាត់ឈឹង, ស្ងប់ឈឹង, ធ្លាក់មាត់ឈឹង* ។

**ឈឹង** ២ *ន.* (ចិ.) ក្តាបមានសណ្ឋានស្រដៀងឬប្រុង: *ដាក់ម៉ឺតំនលើឈឹង* ។

**ឈឹប** *ឧ.* ស្នូរសំឡេងឮដោយបាត់ខ្លឹមឬស្លាកជាដើម: *បាត់ឈឹប ! ស្ងួរឈឹប !*

**ឈឺ** *កុ.* ដែលមានជំងឺ ។ *កិ.* ជាប់ជំងឺ, ទទួលរងជំងឺ ។ *ឈឺចិត្ត* ក្តៅចិត្តហាក់ដូចជាកើតជាប់ឈឺផ្សា ។

**ឈឺឆ្អាល** *កិ.* យកអាសា, ជួយធ្វើកិច្ចការ, ជួយដោះទុក្ខធុរៈផ្សេងៗ : *ត្រូវជួយឈឺឆ្អាលគ្នាផង* ។

**ឈុត** *ន.* (ស. ឝុត អ.ចិ. ឈុត) ពាក្យសម្រាប់ប្រើហៅរបស់ដែលប្រមូលប្រមូលជាពួកមួយ, ជា ១ គ្រឿង : *វែន ១ ឈុត, ចាន ១ ឈុត* ។ រឿងមួយៗ ឬសម្ភាក់រឿងមួយៗ : *ល្ខោនលេងរឿង ១ ឈុត, ឈុតទី ១, ឈុតទី ២* ។

**ឈូ** *ឧ.* ស្នូរសន្ធឹកទឹកហូរខ្លាំងឬសន្ធឹកភ្លៀងធំជាដើម ។ *កិ. វិ.* ពង់ពង, ខ្ពុំ : *ឆ្អើលឈូ* ។

**ឈូក** *ន.* ផលផកាតិពួកមួយ ដើមវែងមានបន្លា, ស្លឹកធំកំពង, ផ្កាប្រើជាគ្រឿងបូជា, ក្រអៅធំរលើមប្រើជាអាហារបានច្រើនយ៉ាង, ឫកក្រងប្រោះយកមេផ្កាកំបាន, ផ្លែប្រើជាអាហារតាមខ្ចីតាមចាស់, ជាក្តុងស្រះ, ត្រពាំង, បឹង តាមកើត ដុះសាយបាយរហ័ស; ឈូកមានច្រើនប្រភេទ គឺ *ឈូកស, ឈូកក្រហម, ឈូកព្រាល* ជាដើម ។ ឈ្មោះស្រុកមួយក្នុងខេត្តកំពត: *ស្រុកឈូក* ។

**ឈូង** *ន.* ឈូងសមុទ្រ, ទន្លេ, ស្ទឹង បឹង ដែលជាញកជាប៉ៀងចូលក្នុងច្រាំង : *ឈូងសមុទ្រ* ។ ប្រអប់តក់ដែលជាក្រឡុងចុងសម្រាប់កាន់បោះ ឬបោលក្នុងល្បែងឈូង : *បោះឈូង, បោលឈូង;* ល្បែងនុះឯងក៏ហៅថា *ឈូង* ដែរ : *លេងឈូង, ច្រៀងឈូង* ។

**ឈូប** *ឧ.* ស្នូរសំឡេងឈាំឮឡើងព្រមទាំងក្រអៅដែលឈូកបាក់ឥរិយាបថៈគេលេងជាល្បែង : *ឈូប! បាក់ឈូប!*

**ឈូឆរ** *កិ. វិ.* ត្អឹម: *មានមនុស្សទៅឈូឆរ, ឆ្អើលឈូឆរ, ជួយឈឺឆ្អាលឈូឆរ* ។

**ឈូឈី** *ន.* ឈ្មោះសម្លទឹកខាប់មួយប្រភេទ ។

**ឈូស** *កិ.* (សំ. *ឈូឞ* "បៀតបៀន, តិយាតៈ ប្រហារ") ចាំង ឆ្ប្រុះដោយដែកឈូស : *ឈូសឈើ* ។ ចូកកំសុលចំងងើង: *យកដីឈូសដី* ។ *ន.* គ្រឿងដែកមានផ្លែមានស្លាក សម្រាប់ឈូស : *ផ្លែដែកឈូស, ស្លាកដែកឈូស, សំណៀនដែកឈូស* ។



**ឈើ** *ន.* អនុជាតិរុក្ខៈពួកមួយ មានច្រើនប្រភេទ ជាពួកហេតុរឹង ដុះលូតលាស់អាស្រ័យឫសដែលចាក់ចុះក្រួចបះកនៈសជាតិនៃដី ទុកដូចជាអាហារឲ្យចរម្រើនលាស់ដើម មែក សម្បក ស្លឹក ផ្លែ, ជាធាតុមានប្រយោជន៍យ៉ាងធំដល់ពួកមនុស្ស ... ។

**ឈើកង់** *ន.* ឈើហុបមានបណ្តោយប្រវែង ១ ម៉ែត្រ ទៅដល់ ៤ ម៉ែត្រ (ហៅតាមទម្លាប់ស្រុក) ។

**ឈើគូក** *ន.* ឈើឫឫស្សីសម្រាប់គូកត្រី មានសម្បូរបោកចិតត់បោះជាដើម ។

**ឈើកៅ** *ន.* ឈ្មោះឈើមួយប្រភេទមានសាច់រឹងស្វិតសម្បុរ-សស្រដៀងនឹងសាច់ភ្លុក ។

**ឈើខ្មៅ** *ន.* ឈ្មោះឈើមួយប្រភេទមានខ្លឹមខ្មៅរលីប ។

**ឈើគូស** *ន.* ប្រដាប់សម្រាប់គូសយកភ្លើង: *ឈើគូស ១ ហោ, ឈើគូស ១ ប្រអប់, ក្រប់ឈើគូស, សម្បកឈើគូស;* (ហៅ *ដែកគូស* ក៏បាន: កាលពីក្នុងសម័យបុរាណ *ប្រើដែកភ្លើង,* ក្នុងសម័យសព្វថ្ងៃនេះ ក៏នៅមានប្រើខ្លះដែរ ព្រោះជារបស់អាចធ្វើកើតដោយងាយមិនបាច់ទិញ, សម្រាប់អ្នកក្រីក្រ) ។

**ឈើចាក់ធ្មេញ** *ន.* ចម្រៀកឈើតូចៗ សម្រាប់ចាក់ដុះឲ្យអស់មន្ទិលដែលជាប់នៅចន្លោះធ្មេញ ។

**ឈើច្រត់** *ន.* ឈើមានចម្ងាយដែកឬស្នាច់ផាក់នៅពល់ ឬឥតចម្ងាយក៏បាន សម្រាប់កាន់ច្រត់ទប់កាយ; ក្នុងវិន័យខាងព្រះពុទ្ធសាសនា មានពុទ្ធានុញ្ញាតឲ្យប្រើបានចំពោះតែភិក្ខុមានជំងឺដែលខានកាន់ឈើច្រត់មិនអាចនឹងដើរបាន, ខ្នាតឈើច្រត់នោះយ៉ាងវែងបានត្រឹមតែប្រវែង ៤ ហត្ថ, ត្រូវឲ្យមានអនុញ្ញាតអំពីជំនុំសង្ឃផងទើបកាន់បាន ។

**ឈើប្រាន** *ន.* ឈើឫឫស្សីស្រួចខ្ចី សម្រាប់ចុះដិកស្ទុំដែលវែងឲ្យមុតមានដារណ្តៅតូចហើយស្គមស្រួច (អ្នកស្រុកខ្លះហៅ *ឈើដុន*) ។

**ឈើជ្រែង** *ន.* ឈើសម្រាប់ទល់ជ្រែងឬឈើដែលទល់, ទប់, ជ្រែងរ៉ៀវកុំឲ្យប្រេតកុំឲ្យរលំ ។

**ឈើឈ្នាន់** *ន.* ឈើសម្រាប់ដាក់ឲ្យតន្ត្របើកបិទ (គ្រឿងតម្បាញ) ។

**ឈើក្រង់** *ន.* សម្តីក្លាយមកពីពាក្យ *ចក្រង្គ* (ម. ក. នោះ) ។ នុះឈប់សែងប្រើតទៅទៀត, ចូរប្រើ *ចក្រង្គ* វិញ ។

**ឈើទាល** *ន.* ឈ្មោះឈើមួយប្រភេទមានជ័រសម្រាប់ធ្វើចន្លុះឬបោះ, បិទ, ពាយូកជាដើម; ឯខ្លឹមសម្រាប់ប្រើជាគ្រឿងទូលស្ពានផ្សេងៗ, ជាឈើមានប្រយោជន៍យ៉ាងសំខាន់ក្នុងកម្ពុជប្រទេស ។

**ឈើទាលត្រាញ់** *ន.* ឈើធំមួយប្រភេទ ច្រើនមានតែនៅក្នុងព្រៃកោះផ្ដាត់ ។ ឈ្មោះឈើតូចមួយប្រភេទទៀត ដើមឫសស្រលូតត្រង់ ដុះលើភ្នំតូច (អ្នកស្រុកខ្លះហៅ *ឈើបុកជាស*) ។

**ឈើពុក ឬ ឈើពុះ** *ន.* ឈើមូលមិនស្រួចសម្រាប់ពុកឬពុះឲ្យមានជាស្នាមក្នុងបាច់ ហើយដាក់គាំទ្រក្រាប់គោល, ក្រាប់សណ្ដែកជាដើម ។

**ឈើផ្លែក** *ន.* ឈើឬឫស្សីដែលសម្រាប់សង្កត់ផ្លែកក្នុងស្រូវចុះឲ្យផ្លែលកបានដើម្បីឲ្យស្រួលច្រូត ។

**ឈើភ្លើង** *ន.* ឈ្មោះឈើមួយប្រភេទមានផ្កាព្រឿងច្រើន, គេច្រើនយកធ្វើជាថ្នាំរក្សា ។

**ឈើរ** *ន.* ឈើដែលចងបន្ទោកគន្លះ (គ្រឿងតម្បាញ)។

**ឈើវែត** *ន.* ឈើដែលចងពីចុងកីមកភ្ជាប់នឹងក្ដោងក្ដារ សម្រាប់វែតគូងតម្បាញ ។

**ឈើសូល** *ន.* (ចា. *សូល*) ឈើស្រួចសម្រាប់ចាក់ទ្រូងសំដីរបស់ក្រុមចោរឆ្លងប្រទូលសាកលត ដែលធ្វើឃាតប់ត-កិច្ច ឲ្យស្រួលដាច់ជេះស្លុល (ហៅតាមទម្លាប់ស្រុកថា *ឈើស្លុល* (ស្លុ) ក៏បាន) ។

**ឈើស្កឹង** (ស្កឹង-ង) *ន.* ឈើសម្រាប់សង្កិនសំពត់គ្រឿងបាក់កជាដើម ។

**ឈើស្ទន់** *ន.* កំណាត់ឈើឬឫស្សីស្រស់ជាដើម សម្រាប់ទំពាដុសធ្មេញឲ្យស្អាតល្អ (ហៅត្រឹមតែ *ស្ទន់* ក៏បាន)។

**ឈើស្រួច** *ន.* ឈើឬឫស្សីដែលគេចិតស្រួចសម្រាប់ក្រសឹកកណ្ដាប់ឬឆ្អឹងជាដើមហើយដោតខ្លួន ។

**ឈើហុប** *ន.* ឈើមិនមានទំហំដែលគេចាំងជា ៤ ជ្រុង ឬសាច់ពែកជា ៤ ជ្រុង (ហៅត្រឹមតែ *ហុប* ក៏បាន) ។

**ឈើអណ្ដាក** *ន.* ឈើស្រួចច្រើនសម្រាប់ដោតពិឃាតមនុស្សដែលមានទោសធំប្រហារជីវិត (មានតែក្នុងសម័យបុរាណកាលប៉ុណ្ណោះ) ។

**ឈើអន្លង** *ន.* ឈើសម្រាប់អន្លងស្បូវឬស្លឹកជាដើម ។

**ឈើអែម** *ន.* ឈ្មោះឈើផ្អែមស្វិតដើមតូច សំបកមានរសផ្អែម សម្រាប់ប្រើជាថ្នាំព្រៃភេសជ្ជៈធ្វើជាដើម ។

**ឈែល ១** *កិ.* ឬ *កិ. វិ.* គន្លងឈ្លែល (ឥ. អា.) ។

**ឈែល ២** *ន.* ពំនើដែលធ្វើឈែល (ឥ. អា.)

*ទ.* ពាក្យអាសគ្រាមដែលនាំអ្នកប្រាថ្នាខ្ពង់ខ្ពស់ ... ពោល សំដៅទៅរកពំនើ ... នោះ ។

**ឈោង** *កិ.* លូកដៃយកចាំងខ្លួន : *ឈោងដៃចាប់, ឈោងដៃបេះផ្កា* ។

**ឈ្មប់** *គុ.* ឬ *កិ. វិ.* ដែលមានក្លិនស្រពោនឆ្អែង ; *ក្រអូបឈ្មប់, ក្លិនឈ្មប់* ។ *ឈ្មុយឈ្មប់* ឈ្មុយឆ្អាង ។

**ឈ្មប់ឈ្មុយ ឬ ឆ្អិតឈ្មុយ** *កិ.* ឬ *កិ. វិ.* ស៊ប់ស្ងាត់, ស្ងៀមស្ងាត់, តាំងបក្តិច : *ធ្វើការឈ្មប់ឈ្មុយ* ឬ *ធ្វើការឆ្អិតឈ្មុយ* ។

**ឈ្មុយ** *គុ.* ឬ *កិ. វិ.* មានក្លិនក្រអូបឈ្ងុយដែលទទួលធុំដែលសុីង, ឪុត, ឆ្អើរ, អាំង ផល់ទៀតសម្បារជាតិ : *ក្លិនឈ្មុយ, ធុំឈ្មុយ, ឆ្ងាយក្លិនឈ្មុយ* ។



**ឈ្មៀម** *គុ.* ឬ *កិ. វិ.* មានក្លិនធុំផ្សាយពីភ្លើង ដែលក្ដៅ : *ក្លិនឈ្មៀម, ធុំឈ្មៀម* ។

**ឈ្មោក** *កិ.* បង្អោន, បន្ទោរក្បាលចាំងខ្លួនទៅមុខ : *ឈ្មោកកាយបង្គំ, ឈ្មោកមើលមុខ* ។

**ឈ្នក់** *ន.* ប្រដាប់នេសាទមច្ឆជាតិមួយប្រភេទ មានសណ្ឋានដូចថង់ មានចំពាស់ ៤ មានដង ១ ។

**ឈ្នាង** *ន.* ឈ្មោះប្រដាប់នេសាទមច្ឆជាតិ; ឈ្នាងមានបីប្រភេទគឺ *ឈ្នាងដង* ធ្វើដោយបន្ទោះឫស្សី មានដង ១ មានកាំងដងសម្រាប់ឱបនឹងកោយត្រីនៅទីទឹករាក់, ទឹកហូរ; *ឈ្នាងដៃ* ឬ *ឈ្នាងផ្លាក់* ធ្វើដោយបន្ទោះឫស្សីសម្រាប់ឱបកោយ (ផ្ញាក់) យកមច្ឆជាតិតូចៗ; *ឈ្នាងក្រាំ* ធ្វើដោយរនាបឫស្សី មានដង ២ មានកាំងងសម្រាប់ឱបកញ្ចប់លើកបានច្រើនដាក់ស្រាក់ក្នុងទឹក ។

**ឈ្នាន់** *ន.* ប្រដាប់សម្រាប់ជាន់, សម្រាប់ទ្រជើង : *ឈ្នាន់កែវសេះ, ឈ្នាន់គោបក្របាន* ។

**ឈ្នានីស ១** *កិ.* ប្រណែន ឫស្យា ចង្អៀត កាត់លោភកាត់ប្រយោជន៍គេ : *កុំឈ្នានីសគេ* ។

**ឈ្នានីស ២** *ន.* អំពើប្រណែន ឫស្យា កាត់លោភកាត់ប្រយោជន៍គេ : *ឈ្នានីសជាអំពើទុច្ចរិត* ។

**ឈ្នុល** *ន.* មុខកំណាត់កាត់បន្ទោះកន្ទុល : *ឈ្នុលកន្ទុល* ។ ប្រដាប់ធ្វើដោយឫស្សីសម្រាប់ទាក់ខ្សែបណ្ដោង, ចងសំណាញ់ : *ឈ្នុលមង, ឈ្នុលសំណាញ់* ។

**ឈ្នុលតង្កៀ** *ន.* ប្រដាប់ធ្វើដោយឈើ មានសណ្ឋានដូចសំប៉ែតកាត់ពុងកណ្ដាល សម្រាប់ផ្គុំតម្បាញ ។

**ឈ្នួត** *ន.* សំពត់សម្រាប់ជូត : *ជូតគ្នីកមុខគេ ក្រវ៉ាត់ឈ្នួតក្បាលចេញ* ។

**ឈ្នួល** *ន.* ថ្លៃដែលជួល; មនុស្សដែលជួលមកប្រើ : *គេយកឈ្នួល ៦០ រៀលក្នុងមួយថ្ងៃ; កេឈ្នួលឲ្យបានតែនៅ* ។

**ឈ្នៀង** *ន.* សំយាបដែលគេពង្រាងចៀមមកជារបៀង ។ ច្រើនថា *ចៀង* ក៏មាន ។

**ឈ្នះ** *កិ.* មានជ័យ, ប្រកបបានភាពលើសគេ : *ឈ្នះក្ដី, ឈ្នះសត្រូវ, ឈ្នះល្បែង* ។

**ឈ្នះឈ្នាន** *គុ.* ឥតយើង, ឈ្នានពោន, ដឹងកោះពញ-ញើរ : *កេងួតាក់នេះឈ្នះឈ្នានណាស់* ។

**ឈ្មុង** *គុ.* ល្អដោយមានសោភ័ណពេញពន្លក, ចំព្រង : *មុខឈ្មុង, កង់ឈ្មុង* ។

**ឈ្មុល** កិ. ឈ្មុលចូល, ស្រុកចូល, ឈ្មៀតចូល, កុះករចូល : *ចោរបើចិតឆ្មៀតយ៉ាងណា ក៏ពុំទំឈ្មុលចូលមកដល់តែបាន* ។

**ឈ្មុស** ១ ន. សត្វជើង ៤ ពួកសំពោច មានទឹកសុក្កៈឬទឹកកាម ក្លិនប្រហើរគេយកសម្រាប់លាយផ្សំធ្វើទឹកអប់ ; ឈ្មុសមានពីរប្រភេទគឺ *ឈ្មុសស្បូវ* ១ ប្រភេទ *ឈ្មុសប្រែង* ១ ប្រភេទ ; ឈ្មុសប្រែងនិងហៅថា *ឈ្មុសទេស* ក៏បាន, ឈ្មុសនេះឯងដែលគេយកទឹកកាមធ្វើទឹកអប់ ។

**ឈ្មុស** ២ កិ. ឈ្ងុយឆាប់ដោយប្រមុះ : *ផ្កាឈ្មុសឆ្ងុំ, ផ្កាឈ្មុសឆ្អឹងខ្យង* ។

**ឈ្មុសទេស** ន. ឈ្មោះគ្រឿងក្រអូបម្យ៉ាងដែលធ្វើអំពីទឹកសុក្កៈឬទឹកកាមឈ្មុសទេស ។

**ឈ្មួញ** ន. អ្នកដែលធ្វើជំនួញ, អ្នកជួញ ។

**ឈ្មួយ** ន. អ្នកជួយ, អ្នកធ្វើការជាជំនួយ (មិនសូវប្រើ) ។

**ឈ្មៀត** កិ. ច្រៀត, ស្រែកចូលទៅក្នុងទីចង្អៀត : *កណ្ដុរឈ្មៀតចូលតាមប្រហោងជញ្ជាំងផ្ទះ* ។

**ឈ្មែ** ន. ឈ្មោះត្រសក់ស្រូវមួយប្រភេទ ផ្លែតូច ពុំសូវមិនជាប់ផ្កា : *ត្រសក់ឈ្មែ* ។

**ឈ្មោល** គុ. ដែលមានភេទជាប្រុស ; និយាយតែពីសត្វតិរច្ឆាន និងដើមឈើខ្លះ : *គោឈ្មោល, សេះឈ្មោល, ក្ដាន់ឈ្មោល, ល្ហុងឈ្មោល* ។ ព. ទ្រ. ញី ។

**ឈ្មោះ** ន. នាមពីពាក្យដែលសន្មតសម្រាប់ហៅមនុស្ស, សត្វ, ទី, របស់ផ្សេងៗ ។

**ឈ្វក់** ១ ឧ. ពាក្យបរិភាសសម្រាប់និយាយផ្សំនឹងពាក្យ ឈ្វី : *ឈ្វក់ឈ្វី* ឬ *ឈ្វីឈ្វក់* គឺច្របូកច្របល់, ទាល់ទី ។

**ឈ្វក់** ២ គិ. ស្ទះដង្ហើមដោយចូលចំហាយ, ដោយទឹក : *ឈ្វក់ផ្សែង, ឈ្វក់ម្ទេស, ឈ្វក់ទឹក* ។

**ឈ្វប** កិ. លបមើលដោយសម្ងាត់, លបស្ដាប់ ។

**ឈ្វប់** គុ. ពាក្យសម្រាប់ផ្ទាំពាក្យងងឹតឲ្យឃើញជាងប្រក្រតី : *ងងឹតឈ្វប់* ងងឹតមើលមិនឃ្លាស់ ។

**ឈ្វម** គុ. (ម. ព. *ផ្សម*) ។

**ឈ្វានពាន** គុ. ដែលមានអាការៈឃើង, រលោភ, បំពានលើ : *មនុស្សឈ្វានពាន, សំដីឈ្វានពាន, កាកើឈ្វានពាន* ។

**ឈ្វាស** គុ. ចិន, ប្រសប់, ស្ទាត់ : *ច្រាញ់ឈ្វាស, គំនិតឈ្វាស, មនុស្សឈ្វាស* ។ *ឈ្វាសវៃ* ចិនរហ័ស, ភ្លៃវៃ (ព្រមជា ឆ្វាត, ឆ្វាស ក៏បាន) ។

**ឈ្វី** កិ. ញ៉ះដោយតែជាងើម ។ *ឈ្វីឈ្វក់* (ម. ព. *ឈ្វក់* ១ ឧ.) ។



**ឈ្វេក** ន. ឈ្មោះដើមឈើមួយប្រភេទ មានខ្ទឹមសម្បុរក្រហម ប្រើធ្វើជាសសរផ្ទះបាន ។

**ឈ្វួស** ន. សត្វព្រៃមួយប្រភេទសណ្ឋានដូចអង្កាំ ។

**ឈ្លើង** ន. សត្វទឹកតតង្គិន ស្បែករុស្ញិតបរ៉េតធំលាយពណ៌លាក់ពាលមនុស្ស, សត្វ : ឈ្លើងមានច្រើនប្រភេទមាន *ឈ្លើងគន្ធាស់* គឺឈ្លើងតូចៗ និង *ឈ្លើងព្រៃត្រែ* ជាឈ្លើងធំៗជាងគេ ។ *ឈ្លើងសមុទ្រ* ឈ្លើងធំៗមានសាច់ក្រាស់ គេប្រើជាអាហារបាន ។

**ឈ្លើយ** ១ ន. ឬ គុ. មនុស្សដែលគេចាប់បានក្នុងទ័ព ឬសត្វដែលគេចាប់បានពីក្នុងព្រៃដោយមានខ្នាក់ ។

**ឈ្លើយ** ២ គុ. ដែលមានអាការព្រៃ, ថ្មឹង : *សម្ដីឈ្លើយ, មុខឈ្លើយ* ។

**ឈ្លៀស** កិ. ស្កាត់ចៀសយានជំនះឬយកមនុស្សមកប្រើជាកងការបណ្ដើរសឹក ដោយបង្ខំការប្រញាប់ប្រញាប់ : *ឈ្លៀសសេះ, ឈ្លៀសគោ, ឈ្លៀសមនុស្ស* ។

**ឈ្លេច** កិ. ចាប់ប្រចាច់ដើម្បីឲ្យបែក, ឲ្យរលៀច, ឲ្យខ្ទេច, ឲ្យស្រុត (ត្រច) ។ *ឈ្លេចឈ្លី* ឈ្លេចហើយឈ្លីផង ។ ព. ប្រ. សង្កត់សង្កិន, ញាំញីឥតប្រណី ។ *ឈ្លេចស្មៅ* នាំគ្នាសង្កត់ដោយអាការខ្ចាតខ្ចាយចំរៀង, ចំហេត ។

**ឈ្លេម** គុ. ដែលឥតមានរសជាតិ : *សម្លសាបឈ្លេម* ។

**ឈ្លេម** គុ. ស្លេម, ស្រួចណាស់ : *ចុងកាំបិតស្រួចឈ្លេម* ។

**ឈ្លោះ** កិ. និយាយប្រកែកតបតជាពាក្យផ្ទុយគ្នាទៅវិញទៅមកដោយកំហឹង ។

**ឈ្វាត** ន. ឈ្មោះត្រីអណ្ដែងមួយប្រភេទ មានស្រកាឆ្វាយតូចក្រៃលែង : *ត្រីឈ្វាត* ។

**ឈ្លៀង** គុ. ថ្ងៃគ្រាន់ពន្លឺ : *វិកាលឈ្លៀង* ។ ម. ព. ទ្រុង, រឹង ឬ ហ្វុង ទៀតផង ។

**ឈ្លៀងយល់** កិ. ពឹងគិតយល់ដោយប្រាជ្ញាដ៏ឈ្លាសវៃ ។

**ឈ្វាំង** ន. ឈ្មោះផ្ដៅមួយប្រភេទ មានសាច់រឹងជាងផ្ដៅឯទៀត : *ផ្ដៅឈ្វាំង* ។